**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** ..............០១៦/១៥..............**ក.ប**/ស.ស.រ

# សេចក្តីសម្រេច

# ស្តីពី

# ការបង្កើតក្រុមការងារ សម្រាប់ទទួលបន្ទុកអនុវត្តគោលនយោបាយអភិវឌ្ឍន៍ ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងលិខិតលេខ៧៣១/១៥ ក.អ.ក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីសំណើសុំបង្កើតអង្គភាពទទួលបន្ទុកគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ១**.-

ត្រូវបានបង្កើតក្រុមការងារ សម្រាប់ទទួលបន្ទុកអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ពេជ សោភ័ន** | រដ្ឋលេខាធិការ | ប្រធាន |
| ២- ឯកឧត្តម **ម៉ម វណ្ណៈ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣- ឯកឧត្តម **ហ៊ី ទុឡារី** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៤- ឯកឧត្តម **ប៉ុក ប៉ាន់** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥- ឯកឧត្តម **ហេង សួរ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម **សេង សក្ដា** | អគ្គនាយកការងារ | សមាជិក |
| ៧- ឯកឧត្តម **ឡៅ ហ៊ីម** | អគ្គនាយកអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

| | | |
|---|---|---|
| ៨- ឯកឧត្តម **ហុង ឿន** | ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ | សមាជិក |
| ៩- លោក **តឹប រឿន** | អគ្គនាយករងអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | សមាជិក |
| ១០- លោក **អ៊ុក សមវិទ្យា** | នាយកបេឡាជាតិរបបសន្តិសុខសង្គម | សមាជិក |
| ១១- លោក **ឃិន ចន្ថា** | ប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា | សមាជិក |
| ១២- លោក **សុភខុន ដាវីដ** | ប្រធាននាយកដ្ឋានធនធានគុណភាព | សមាជិក |
| ១៣-លោក **ហ៊ីង ស៊ីដេត** | ប្រធាននាយកដ្ឋានបណ្តុះបណ្តាល | សមាជិក |
| ១៤-លោកស្រី **សៅ សុគន្ធកេត្យា** | ប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ | សមាជិក |
| ១៥-លោក **ឆាង សាក់** | ប្រធាននាយកដ្ឋានស្តង់ដានិងកម្មវិធីសិក្សា | សមាជិក |
| ១៦-លោកស្រី **នង កណ្ណិកា** | ប្រធាននាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ | សមាជិក |
| ១៧-លោក **ឆាយ សុភា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា | សមាជិក |
| ១៨-លោក **សា ភិន្នវីឌី** | អនុប្រធាននាយកដ្ឋានគោលនយោបាយនិងយុទ្ធសាស្ត្រ | សមាជិក |

**ប្រការ២**.-

ក្រុមការងារគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានភារកិច្ចដូចខាងក្រោម ៖

- សហការដឹកនាំ ត្រួតពិនិត្យភារកិច្ចពាក់ព័ន្ធរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥
- រៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីពិនិត្យ វាយតម្លៃលើរបាយការណ៍អនុវត្តភារកិច្ចរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្ញើជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលទទួលបន្ទុកគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥
- សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬអនុប្រធាន តាមការចាំបាច់
- ទទួលអនុវត្តភារៈកិច្ចចាំបាច់ផ្សេងៗទៀតដែលឯកឧត្តមរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៣**.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ និងនាយកបេឡាជាតិរបបសន្តិសុខសង្គម ព្រមទាំង ឯកឧត្តម អស់លោក លោកស្រី ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន៖**

-ថ្នាក់ដឹកនាំទទួលបន្ទុក

-ដូចប្រការ៣ "ដើម្បីអនុវត្ត"

-ឯកសារ-កាលប្បវត្តិ